សួស្តី! នៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីការញ៉ាំកាហ្វេ។ អញ្ចឹងភាគច្រើន ប្រជាជនកម្ពុជា គាត់ចូលចិត្តញ៉ាំកាហ្វេ ហើយកាហ្វេដែលគាត់ចូលចិត្តញ៉ាំហ្នឹង ភាគច្រើនគឺញ៉ាំនៅតាមហាង ព្រោះគាត់អត់សូវមានពេលឆុងខ្លួនឯងទេ។ ប៉ុន្តែមានអ្នកខ្លះគាត់ចូលចិត្តទិញកាហ្វេ គ្រាប់កាហ្វេមក ដើម្បីឆុងខ្លួនឯងញ៉ាំនៅផ្ទះ។ តែយើងភាគច្រើនគឺញ៉ាំនៅហាង អាចជាហាងតូចៗ ឬក៏ជាហាងធំៗ ហើយអ្នកខ្លះទៀតគាត់ចូលចិត្តញ៉ាំតាមរទេះ បានន័យថានៅកម្ពុជា ក៏មានការលក់កាហ្វេតាមរទេះផងដែរ អញ្ចឹងប្រសិនបើយើងអត់ចង់ទៅហាង យើងអាចទិញតាមរទេះបាន នៅពេលដែលគេមកលក់ក្បែរផ្ទះយើង ឬក៏យើងឃើញនៅតាមផ្លូវ យើងអាចឈប់ទិញបាន ដោយមានតម្លៃថោកផងដែរ យើង[...] ឬហៅថាមានតម្លៃសមរម្យ។

អញ្ចឹងជាក់ស្តែងយើងមកមើលរូបភាពទី ១ នៅក្នុងរូបភាពទី ១ យើងឃើញមានបុរសម្នាក់ កំពុងតែដើរជាមួយនឹងក្មេងស្រីម្នាក់ទៀត ដែលក្មេងស្រីម្នាក់នោះ យើងឃើញគាត់មានអាយុប្រហែលជា ៥ ឆ្នាំ អញ្ចឹងគាត់ជាក្មេងស្រីតូច ដែលក្មេងស្រីម្នាក់នោះ គាត់ពាក់អាវសដៃវែង ខោជើងវែងពណ៌ខ្មៅ អញ្ចឹងគាត់ដើរ ហើយគាត់ចងសក់ទីទុយ ដោយនៅក្បែរក្មេងស្រីម្នាក់ហ្នឹង គឺគាត់ មានបុរសម្នាក់ទៀត អញ្ចឹងក្មេងស្រីហ្នឹង គាត់ចងសក់ទីទុយ បានន័យថាចងសក់ឆ្វេងមួយ ស្តាំមួយ បះឡើងទៅលើ ដែលសក់បែបនេះ គឺគេប្រើប្រាស់សម្រាប់ក្មេងៗ បានន័យថាក្មេងស្រីគឺចូលចិត្តធ្វើសក់បែបនេះណាស់ ព្រោះធ្វើសក់បែបនេះ មើលទៅគឺគួរឲ្យស្រឡាញ់។ អញ្ចឹងក្មេងស្រីនោះគឺមានសក់ចងសក់ទីទុយ។ ហើយនៅក្បែរក្មេងស្រីម្នាក់ហ្នឹងគឺមានបុរសម្នាក់ ដែលគាត់អាយុប្រហែលជា ៣០ ឆ្នាំ អញ្ចឹងបុរសនោះអាចជាឪពុករបស់ក្មេងស្រីម្នាក់នោះ។ ដោយបុរសម្នាក់ហ្នឹង គាត់ពាក់អាវពណ៌លឿងដៃខ្លី ហើយស្លៀកខោជើងវែងពណ៌ស អញ្ចឹងពួកគាត់ទាំងពីរកំពុងតែដើរនៅតាមផ្លូវ ដែលយើងឃើញខាងក្រោយខ្នងរបស់ពួកគាត់ទាំងពីរ គឺជាស្រមោលនៃទីក្រុង។ អញ្ចឹងបានន័យថាពួកគាត់អាចជាមនុស្សដែលរស់នៅក្នុងទីក្រុង ដែលជាមនុស្សរស់នៅក្នុងទីក្រុង ហើយពួកគាត់កំពុងតែដើរនៅតាមផ្លូវ ដើម្បីដើរកម្សាន្តនៅថ្ងៃសម្រាក ឬក៏នៅថ្ងៃអាទិត្យ ព្រោះថាក្មេងស្រីនេះគឺជាកូនក្មេង ដូច្នេះប្រសិនបើថ្ងៃធម្មតាគឺគាត់ត្រូវទៅរៀន អញ្ចឹងនៅពេលដែលសម្រាក គឺឪពុកគាត់នាំគាត់មកដើរលេង។ អញ្ចឹងគាត់កំពុងតែដើរជាមួយនឹងឪពុកគាត់ ដោយបុរសម្នាក់នោះ គាត់ដើរដឹកដៃក្មេងស្រីនោះយ៉ាងជាប់ បានន័យថាគាត់ដើរកាន់ដៃកូនស្រីគាត់យ៉ាងជាប់ ខ្លាចវង្វេង។ អញ្ចឹងពេលយើងដើរលេងជាមួយក្មេង យើងត្រូវកាន់ដៃក្មេងឲ្យជាប់ ព្រោះប្រសិនបើយើងកាន់អត់ជាប់ទេ យើងអាចនឹងវង្វេងគ្នា អញ្ចឹងធ្វើឲ្យយើងបាត់មនុស្សបាន។ អញ្ចឹងនៅក្នុងរូបភាពទី ១ បានន័យថាគាត់ដើរជុំវិញទីក្រុង ឬក៏គាត់ដើរក្បែរៗទីក្រុង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឬក៏ចេញឆ្ងាយពីទីក្រុងបន្តិច ដើរលេងនៅថ្ងៃអាទិត្យ ជាមួយនឹងកូនស្រីរបស់គាត់។ ដោយគាត់បុរសម្នាក់ហ្នឹង គាត់ដើរកាន់ដៃកូនស្រីរបស់គាត់យ៉ាងជាប់។

បន្ទាប់មកទៀតរូបភាពទី ២ រូបភាពទី ២ នៅពេលដែលពួកគេដើរបានបន្តិចក្រោយមក ពួកគេក៏បានដើរមកដល់ហាងកាហ្វេមួយ។ អញ្ចឹងបានន័យថាពួកគេនៅថ្ងៃអាទិត្យ ឬក៏ថ្ងៃឈប់សម្រាកនេះ បុរសម្នាក់នោះ គាត់បានដឹកដៃកូនស្រីរបស់គាត់មកហាងកាហ្វេ ដើម្បីញ៉ាំកាហ្វេ។ អញ្ចឹងយើងឃើញនៅក្នុងរូបភាពទី ២ គឺបុរសម្នាក់នោះ គាត់បានចង្អុលបង្ហាញទៅកាន់កូនស្រីរបស់គាត់នូវហាងកាហ្វេមួយ ដែលយើងឃើញ បុរសដែលពាក់អាវលឿង ពាក់អាវដៃខ្លីពណ៌លឿងនិងស្លៀកខោជើងវែងពណ៌ស គាត់បានយកដៃឆ្វេងរបស់គាត់ចង្អុលទៅហាងកាហ្វេមួយកន្លែង ហើយដៃស្ដាំរបស់គាត់កំពុងតែកាន់ដៃកូនស្រីរបស់គាត់ ហើយគាត់បានងាកមកនិយាយជាមួយនឹងកូនស្រីរបស់គាត់ ដោយគាត់ប្រហែលជាបបួលកូនស្រីរបស់គាត់ដើម្បីចូលទៅក្នុងហាង ឬក៏គាត់សួរទៅកូនស្រីរបស់គាត់ថាចង់ចូលទៅញ៉ាំកាហ្វេ ឬក៏ចង់ចូលទៅញ៉ាំភេសជ្ជៈអ្វីដែរឬទេនៅក្នុងហាង? អញ្ចឹងបន្ទាប់ពីពួកគាត់ដើរមកដល់ហាងកាហ្វេមួយកន្លែងនោះហើយ បុរសម្នាក់ហ្នឹង គាត់ក៏បានចង្អុលទៅហាងកាហ្វេ។ ដែលយើងឃើញហាងកាហ្វេនោះ គឺនៅខាងលើ គឺមានផ្លាកសញ្ញា ដែលផ្លាកសញ្ញាគឺសរសេរថា ហាងកាហ្វេ។ អញ្ចឹងអក្សរអង់គ្លេស នៅខាងលើខ្លោងទ្វារគឺជាអក្សរអង់គ្លេស ឬក៏អក្សរអង់គ្លេស អញ្ចឹងដែលមានន័យជាភាសាខ្មែរថា ហាងកាហ្វេ។ អញ្ចឹងយើងឃើញនៅខាងមាត់ទ្វារគឺមានក្រណាត់ជូតជើងមួយ អញ្ចឹងក្រណាត់ជូតជើងនេះទុកសម្រាប់នៅពេលដែលភ្ញៀវចូល គាត់អាចជូតជើងគាត់បាន ព្រោះថាពេលខ្លះស្បែកជើងភ្ញៀវខ្លះ គាត់មានដីច្រើន អញ្ចឹងហាងកាហ្វេគឺជាកន្លែងញ៉ាំ ឬក៏ជាកន្លែងញ៉ាំកាហ្វេ អញ្ចឹងប្រសិនបើមានដីចូលច្រើនគឺអត់ល្អទេ បានន័យថាគគ្រិចហាង ឬក៏បានន័យថាធ្វើឲ្យភ្ញៀវផ្សេងៗគាត់អត់ពេញចិត្ត។ អញ្ចឹងភ្ញៀវទាំងអស់ នៅពេលដែលចូល គាត់អាចជាន់លើក្រណាត់ជូតជើងដែលនៅមាត់ទ្វារនោះ ដើម្បីសម្អាតស្បែកជើងរបស់គាត់ជាមុនសិន ដើម្បីកុំឲ្យប្រឡាក់ហាង ឬក៏ដើម្បីកុំឲ្យខ្វះអនាម័យ។ ហើយនៅក្បែរទ្វារយើងឃើញមានបង្អួចមួយផងដែរ អញ្ចឹងជាទូទៅហាងកាហ្វេតែងតែមានបង្អួច ដើម្បីឲ្យភ្ញៀវនៅខាងក្នុងមើលឃើញទេសភាពនៅខាងក្រៅ។ ដែលយើងឃើញ បុរសម្នាក់ហ្នឹង គាត់កំពុងតែចង្អុលប្រាប់កូនស្រីរបស់គាត់អំពីហាងកាហ្វេ ហើយគាត់បានបបួលកូនស្រីរបស់គាត់ចូលទៅញ៉ាំកាហ្វេនៅក្នុងហាងកាហ្វេនោះ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញថា បុរសម្នាក់នោះ
គាត់បានដឹកដៃកូនស្រីរបស់គាត់ចូលមកដល់ហាងកាហ្វេ
អញ្ចឹងគាត់បានចូលមកក្នុងហាងកាហ្វេតាមខ្លោងទ្វារ ហើយគាត់នៅតែកាន់ដៃកូនស្រីយ៉ាងជាប់
ព្រោះបុរសម្នាក់នោះគាត់ខ្លាចកូនស្រីរបស់គាត់វង្វេង គាត់បាត់ ឬក៏គាត់បាត់កូនស្រីគាត់
ហើយម្យ៉ាងវិញទៀត ដោយសារតែនាងនៅក្មេង អញ្ចឹងប្រសិនបើគាត់លែងដៃ
នាងអាចរត់លេងផ្តេសផ្តាស ឬក៏អាចរត់ទៅតាមផ្លូវ អញ្ចឹងប្រសិនបើគាត់រត់ទៅតាមផ្លូវ
អាចធ្វើឲ្យមានឡាន ឬក៏ម៉ូតូប៉ះ ឬក៏បុកគាត់ អញ្ចឹងអាចធ្វើឲ្យគាត់មានគ្រោះថ្នាក់បាន ដូច្នេះ
ដើម្បីរក្សាសុវត្ថិភាពកូនស្រីរបស់គាត់ផង និងដើម្បីកុំឲ្យវង្វេងផង
គាត់ត្រូវកាន់ដៃកូនស្រីរបស់គាត់ឲ្យជាប់ ទោះបីជាចូលដល់ក្នុងហាងកាហ្វេក៏ដោយ
ព្រោះពេលខ្លះនៅក្នុងហាងកាហ្វេគឺមានមនុស្សច្រើន អញ្ចឹងក្មេងស្រីអាចវង្វេង
ដោយសារតែនាងនៅតូចពេក អញ្ចឹងនាងអាចវង្វេងបាន អញ្ចឹងយើងត្រូវតែកាន់ដៃរបស់នាង
ដើម្បីកុំឲ្យនាងវង្វេង។ ដែលនៅក្នុងហាងកាហ្វេ នៅក្បែរទ្វារ យើងឃើញមានគេតាំងរូបថតជាច្រើន
អញ្ចឹងដើម្បីលម្អនៅក្នុងហាង ម្ចាស់ហាងបានដាក់តាំងរូបថតជាច្រើននៅក្បែរទ្វារនិងក្បែរបង្អួច។
ហើយយើងឃើញនៅក្នុងរូបភាពទី ៣ នេះដដែល គឺមានតុជាច្រើន
កំពុងតែដាក់នៅក្នុងហាងកាហ្វេនោះ ដែលយើងឃើញនៅខាងស្តាំដៃ នៅខាងឆ្វេងដៃ
គឺមានមនុស្សពីរនាក់ មនុស្សប្រុសស្រីពីរនាក់ កំពុងតែអង្គុយញ៉ាំកាហ្វេនៅក្នុងហាងនោះផងដែរ
ដែលពួកគេកំពុងតែអង្គុយនៅលើកៅអី ហើយនៅខាងមុខរបស់ពួកគេ គឺមានតុចំនួនមួយ
ដែលនៅលើតុនោះគឺមានកែវកាហ្វេចំនួនពីរ ហើយពួកគេញ៉ាំកាហ្វេបណ្តើរ និយាយគ្នាបណ្តើរ
អំពីការងារ ឬក៏អំពីការសិក្សា។ អញ្ចឹងយើងឃើញភ្ញៀវនៅក្នុងហាងកាហ្វេនោះច្រើន
ហើយនៅខាងស្តាំដៃវិញ យើងឃើញមានតុទំនេរចំនួនមួយ ហើយមានកៅអីចំនួនពីរ
ដែលយើងឃើញមានអ្នកបម្រើ ឬអ្នករត់តុនៅក្បែរតុនោះផងដែរ។ អញ្ចឹងអ្នកបម្រើ
ឬអ្នករត់តុបានហៅឪពុកនិងកូន បុរសដែលអាចជាឪពុក និងក្មេងស្រីនោះ ឲ្យចូលទៅអង្គុយតុ។
ដោយសារតែគាត់ឃើញអតិថិជនចូលក្នុងហាង
ដូច្នេះអ្នកបម្រើត្រូវតែមានការរួសរាយរាក់ទាក់ទៅរកអតិថិជន
អញ្ចឹងគាត់ត្រូវតែរួសរាយរាក់ទាក់ទៅរកអតិថិជន ហើយហៅអតិថិជនចូលឲ្យ
ឲ្យចូលមកអង្គុយនៅលើតុ ឲ្យចូលមកអង្គុយនៅលើតុ។ ដែលជាក់ស្តែង
យើងឃើញអ្នកបម្រើនៅក្នុងរូបភាពនេះកំពុងតែប្រាប់ទៅដល់ឪពុកនិងកូននោះ
គាត់ប្រាប់អំពីកៅអីដែលនៅទំនេរ និងតុដែលនៅទំនេរ។ យើងឃើញបុរសដែលជាអ្នកបម្រើ
គឺគាត់ពាក់អាវស ដៃខ្លី និងខោសជើងវែង ហើយគាត់ពាក់អៀមមួយ ក្រណាត់អៀមពណ៌ខៀវមួយ
ដែលក្រណាត់អៀមពណ៌ខៀវនោះ គឺការពារកុំឲ្យសម្លៀកបំពាក់គាត់ប្រឡាក់
នៅពេលដែលគាត់លើកកាហ្វេ ឬក៏នៅពេលដែលគាត់ជូតតុ។ ដោយសារតែគាត់ជាអ្នកបម្រើ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូច្នេះវាងាយស្រួលនឹងធ្វើឲ្យប្រទ្បាក់ខោអាវគាត់ ដូច្នេះគាត់ត្រូវតែពាក់អៀមក្រណាត់មួយ ដើម្បីការពារកុំឲ្យប្រទ្បាក់។ ហើយយើងឃើញនៅលើដៃខាងឆ្វេងរបស់គាត់ គឺគាត់កំពុងតែកាន់ក្រណាត់មួយពណ៌លឿង អញ្ចឹងក្រណាត់នៅលើដៃរបស់គាត់ គឺគាត់ទុកសម្រាប់ជូតតុ នៅពេលដែលមានភ្ញៀវចេញពីតុ គាត់ប្រមូលកែវហើយ គាត់យកក្រណាត់នោះមកជូតតុ សម្អាតតុ ដើម្បីឲ្យមានភ្ញៀវក្រោយចូលមកអង្គុយបានស្រួល។

បន្ទាប់មកទៀតរូបភាពទី ៤ រូបភាពទី ៤ បន្ទាប់ពីភ្ញៀវ ហៅភ្ញៀវចូលតុហើយ អញ្ចឹងបន្ទាប់ពីអ្នកបម្រើម្នាក់នោះ គាត់ហៅភ្ញៀវរបស់គាត់ចូលតុទាំងពីរនាក់រួចហើយ គាត់ក៏បានឲ្យភ្ញៀវអង្គុយនៅលើកៅអី អញ្ចឹងយើងឃើញនៅក្នុងរូបភាពទី ៤ គឺក្មេងស្រីនោះកំពុងតែអង្គុយលើកៅអីមួយ ហើយបុរសដែលជាឪពុកកំពុងតែអង្គុយលើកៅអីមួយ ដោយពួកគេអង្គុយទល់មុខគ្នាដោយមានតុនៅកណ្តាល។ អញ្ចឹងពួកគេអង្គុយទល់មុខគ្នា ហើយមានតុនៅកណ្តាល ដោយអ្នកបម្រើកំពុងតែកាន់ប៊ិចនិងសៀវភៅដើម្បីកត់ត្រា។ អញ្ចឹងនៅក្នុងរូបភាពទី ៤ នេះ គឺអ្នកបម្រើកំពុងតែសួរទៅកាន់បុរសដែលជាឪពុកថា តើគាត់ត្រូវការពិសាអ្វី អញ្ចឹងគាត់សួរបណ្តើរ គឺដៃឆ្វេងរបស់[គាត់] ដៃឆ្វេងរបស់គាត់គឺកាន់ប៊ិច ហើយដៃស្តាំរបស់គាត់គឺកំពុងតែកាន់សៀវភៅកំណត់ត្រា។ អញ្ចឹងគាត់កាន់ធ្វើបែបនេះ ដើម្បីឲ្យច្បាស់ថាភ្ញៀវត្រូវការអ្វី គាត់នឹងសរសេរទុក អញ្ចឹងគាត់អាចទៅធ្វើឬក៏ទៅកុម្ម៉ង់ពីចុងភៅ ឲ្យគេធ្វើកាហ្វេឬក៏ធ្វើអ្វីបានតាមតម្រូវការរបស់ភ្ញៀវ ព្រោះប្រសិនបើគាត់អត់កត់ទេ គាត់អាចនឹងភ្លេចបាន គាត់អាចនឹងភ្លេចបាន។ អញ្ចឹងនៅក្នុងរូបភាពទី ៤ គឺបុរសម្នាក់នោះ គាត់បានហៅកាហ្វេខ្មៅ។ ដែលជាទូទៅគឺយើង នៅកម្ពុជាគឺយើងចូលចិត្តមានកាហ្វេពីរប្រភេទ គឺកាហ្វេខ្មៅនិងកាហ្វេលាយទឹកដោះគោ។ អញ្ចឹងអ្នកខ្លះគាត់ចូលចិត្តល្វីង ដូច្នេះគាត់ហៅកាហ្វេខ្មៅដើម្បីញ៉ាំ ប៉ុន្តែអ្នកខ្លះគាត់អត់សូវចូលចិត្តល្វីង ដូច្នេះគាត់ហៅកាហ្វេលាយទឹកដោះគោ ដែលមានរសជាតិទឹកដោះគោផងកាហ្វេផង។ អញ្ចឹងនៅក្នុងរូបភាពនេះគឺ បុរសដែលជាឪពុក គាត់បានលើកដៃឡើង គាត់បានលើកដៃឡើង ហើយប្រាប់ទៅអ្នកបម្រើថាគាត់ត្រូវការកាហ្វេខ្មៅមួយកែវ។ ដែលយើងឃើញគាត់បានគិតទៅដល់កាហ្វេខ្មៅ ដែលមានកំពុងផ្សែងហុយ ហុយនៅលើកែវ ដែលមើលទៅគឺគួរឲ្យចង់ញ៉ាំ បានន័យថាមើលទៅគឺឈ្ងុយកាហ្វេ [ដែលកាហ្វេ] កែវកាហ្វេគឺទ្រដោយចានកាហ្វេ។ អញ្ចឹងជាធម្មតា កែវកាហ្វេ គឺយើងត្រូវតែមានចានមួយ ដើម្បីទ្រផងដែរ ដើម្បីកុំឲ្យវាខ្វាយ។ អញ្ចឹងនៅក្នុងរូបភាពនេះ បុរសដែលជាឪពុក បុរសដែលជាឪពុក គាត់បានហៅកាហ្វេខ្មៅមួយកែវ ហើយគាត់បានប្រាប់ទៅ អ្នកទិញ ឬក៏អ្នក គាត់បានប្រាប់ទៅអ្នកបម្រើ។ អញ្ចឹងគាត់បានប្រាប់ទៅអ្នកបម្រើ ដើម្បីហៅកាហ្វេខ្មៅមួយកែវ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៥ នៅក្នុងរូបភាពទី ៥
បន្ទាប់ពីអ្នកបម្រើបានសួរទៅកាន់បុរសដែលជាឪពុករួចរាល់ហើយ
អញ្ចឹងគាត់បានងាកមកសួរក្មេងស្រីនោះម្ដង ថាតើក្មេងស្រីនោះចង់ញ៉ាំអ្វី អញ្ចឹងក្មេងស្រីនោះ
គាត់ក៏បានប្រាប់ទៅដល់អ្នកបម្រើថា គាត់ប្រហែលជាចង់ញ៉ាំកូកាកូឡា ឬក៏ទឹកក្រូចផ្សេងៗ។
អញ្ចឹងដោយសារតែគាត់ជាក្មេង អញ្ចឹងនៅពេលដែលក្មេងគឺគាត់អត់ចូលចិត្តញ៉ាំកាហ្វេនោះទេ
ព្រោះកាហ្វេ គឺសម្រាប់តែមនុស្សធំតែប៉ុណ្ណោះ ប្រសិនបើក្មេងញ៉ាំ គឺអាចប៉ះពាល់ដល់សុខភាពបាន។
អញ្ចឹងគាត់ចង់ញ៉ាំជាទឹកក្រូចវិញ គាត់អត់ចង់ញ៉ាំកាហ្វេដូចប៉ារបស់គាត់ទេ។
ដែលយើងឃើញគាត់កុម្ម៉ង់ដូចជាកូកាកូឡា ឬក៏ Fanta ឬក៏ Sprite ជាដើម ដើម្បីញ៉ាំ។

បន្ទាប់មកទៀតរូបភាពទី ៦ នៅក្នុងរូបភាពទី ៦ បន្ទាប់ពីទទួលការកុម្ម៉ង់ពីអតិថិជនហើយ
បុរសដែលជាម្ចាស់ហាង ឬក៏បុរសដែលជាអ្នកបម្រើនោះ
គាត់បានដើរទៅយកអ្វីដែលភ្ញៀវគាត់បានកុម្ម៉ង់ អញ្ចឹងយើងឃើញគាត់ដើរត្រលប់មកវិញ
ដោយដៃរបស់គាត់ទាំងពីរ គឺទ្រនូវថាសមួយ។ អញ្ចឹងដោយសារតែភ្ញៀវបានកុម្ម៉ង់ច្រើន
ដែលមានដូចជាកាហ្វេ មានដូចជាទឹកក្រូច មានដូចជាកែវទឹកកកផងដែរ ដូច្នេះ គាត់កាន់អត់អស់ទេ
ដៃគាត់តែពីរ គាត់មានដៃតែពីរ អញ្ចឹងគាត់កាន់ទាំងអស់អត់អស់ទេ ដូច្នេះគាត់ប្រើប្រាស់ថាស។
ដែលយើងឃើញគាត់កាន់ថាស ថាសគឺជាបន្ទះធំមួយ ដែលធ្វើអំពីដែក ឬក៏ធ្វើអំពីជ័រ
ដែលអាចធ្វើឲ្យយើងដាក់បានរបស់របរច្រើន ដែលវាមានរាងសំប៉ែត ហើយធំ អាចមានរាងជ្រុង
ឬក៏មានរាងមូល ទៅតាមប្រភេទរបស់វា។ អញ្ចឹងនៅក្នុងរូបភាពទី ៦ យើងឃើញអ្នកបម្រើម្នាក់នោះ
គាត់កាន់ថាសមូលមួយ ហើយគាត់ដាក់កាហ្វេ ដាក់កែវទឹកកក និងដាក់ទឹកក្រូចមួយកំប៉ុង
ទៅលើថាសនោះ និងកាន់យកមកឲ្យអតិថិជនរបស់គាត់។ អញ្ចឹងដោយសារតែគាត់កាន់អត់អស់
គាត់កាន់អត់អស់ គាត់ប្រើប្រាស់ថាសជំនួស។ អញ្ចឹងគាត់យកថាសមកដាក់ទឹកក្រូច និងកាហ្វេនោះ
ជំនួសឲ្យការកាន់ដោយដៃវិញ ព្រោះដើម្បីឲ្យកាន់បានម្ដងទាំងអស់តែម្ដង។

បន្ទាប់មកទៀតរូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញថា បន្ទាប់ពីពួកគាត់ទទួលបានទឹកក្រូច
និងទទួលបានកាហ្វេរួចរាល់ហើយ យើងឃើញបុរសដែលជាឪពុក
ក៏បានគាស់ទឹកក្រូចឲ្យកូនស្រីរបស់គាត់ ហើយចាក់ចូលទៅក្នុងកែវទឹកកក។
អញ្ចឹងដោយសារតែកូនស្រីរបស់គាត់គឺតូច នាងនៅតូចពេក ដោយសារតែនាងទើបតែអាយុប្រាំឆ្នាំ
ដូច្នេះនាងអត់ចេះគាស់ទឹកក្រូចទេ ហើយពេលខ្លះ ប្រសិនបើក្មេងៗគាត់គាស់ទឹកក្រូច
គឺអាចមានគ្រោះថ្នាក់បាន ដោយសារតែកំប៉ុងទឹកក្រូច គឺធ្វើអំពីអាលុយមីញ៉ូម
ដូច្នេះប្រសិនបើក្មេងគាស់ វាអាចនឹងមុតដៃ គាត់អាចនឹងមុតដៃនឹងកំប៉ុងបាន
អញ្ចឹងយើងជាមនុស្សចាស់ មនុស្សចាស់ត្រូវធ្វើឲ្យក្មេង បានន័យថា គាត់ត្រូវគាស់ឲ្យក្មេង។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលជាក់ស្តែងយើងឃើញនៅក្នុងរូបភាពទី ៧ គឺឪពុកម្នាក់នោះ
គាត់បានគាស់ទឹកក្រូចឲ្យកូនស្រីរបស់គាត់ រួចចាក់ទឹកក្រូចនោះចូលទៅក្នុងកែវទឹកកកមួយ។
អញ្ចឹងដោយសារតែទឹកក្រូច គឺជា មិនមែនជាទឹកក្រូចដែលត្រជាក់ស្រាប់
ដូច្នេះគាត់ត្រូវការចាក់ចូលទៅក្នុងកែវទឹកកក ដើម្បីឲ្យវាត្រជាក់។
ដោយយើងឃើញកែវមួយនៅទីនេះគឺមានដាក់ទឹកកកនៅក្នុងនោះផងដែរ
និងមានបំពង់បឺតចំនួនមួយ។ អញ្ចឹងគេអាចញ៉ាំទឹកក្រូចនោះដោយសារបំពង់បឺត [...] បឺត [...]
បំពង់បឺត ដោយគេមិនចាំបាច់យកមាត់របស់គេមកញ៉ាំផ្ទាល់នឹងកែវនោះទេ។ អញ្ចឹងគេបឺតបំពង់បឺត
ហើយគេអត់ចាំបាច់ញ៉ាំផ្ទាល់ទៅនឹងកែវនោះទេ។ អញ្ចឹងរូបភាពទី ៧
គឺគាត់កំពុងតែចាក់ទឹកក្រូចចូលទៅក្នុងកែវ ដើម្បីឲ្យមាន ឲ្យវាត្រជាក់ជាមួយនឹងទឹកកក។
អញ្ចឹងគាត់ចាក់ទឹកក្រូចចូលក្នុងកែវឲ្យត្រជាក់ជាមួយនឹងទឹកកក ដើម្បីឲ្យកូនស្រីរបស់គាត់ញ៉ាំ។

បន្ទាប់មកទៀតរូបភាពទី ៨ រូបភាពទី ៨ យើងឃើញថា
បន្ទាប់ពីគាត់ចាក់ទឹកក្រូចចូលទៅក្នុងកែវរួចរាល់ហើយ
យើងឃើញកូនស្រីរបស់គាត់បានយកដៃទាំងពីរ ក្មេងស្រីម្នាក់នោះ គាត់បានយកដៃទាំងពីរ
ឬក៏ទាំងសងខាង កាន់កែវឡើង អញ្ចឹងដោយសារតែគាត់តូច អញ្ចឹងដៃរបស់គាត់គឺអត់ធំទេ
ដូច្នេះដើម្បីឲ្យជាប់ កាន់កែវឲ្យជាប់ គាត់ត្រូវប្រើប្រាស់ដៃពីរដើម្បីកាន់។
ដែលជាក់ស្តែងយើងឃើញរូបភាពនេះ គឺគាត់កំពុងតែកាន់កែវដោយដៃទាំងពីរ ហើយមាត់របស់គាត់
គឺបឺតនឹងបំពង់បឺត។ បានន័យថាក្នុងកែវមានបំពង់បឺតមួយ សម្រាប់ឲ្យគាត់បឺតទឹកក្រូច។
ដោយសារតែទឹកក្រូចត្រជាក់ ដូច្នេះយើងអាចបឺតតាមបំពង់បឺតបាន។ អញ្ចឹងទឹកក្រូច
នៅពេលដែលដាក់ជាមួយនឹងទឹកកក គឺទឹកក្រូចនោះគឺត្រជាក់ គឺងាយស្រួលញ៉ាំ បានន័យថាឆ្ងាញ់
យើងអាចញ៉ាំបានឆ្ងាញ់ ប្រសិនបើយើងអត់ញ៉ាំដោយដាក់ទឹកកកទេ គឺមានជាតិហ្គាសខ្លាំង
បានន័យថាជាតិហ្គាសខ្លាំង អញ្ចឹងយើងញ៉ាំទៅអត់សូវឆ្ងាញ់ទេ។ ប៉ុន្តែប្រសិនបើវាត្រជាក់
ឬក៏យើងញ៉ាំជាមួយទឹកកកគឺឆ្ងាញ់។ ដែលជាក់ស្តែងក្មេងស្រីម្នាក់នេះ គាត់កំពុងតែញ៉ាំទឹកក្រូច
ដែលដាក់នៅក្នុងទឹកកក ដែលចាក់ចូលទៅក្នុងទឹកកក ហើយគាត់បានញ៉ាំទឹកក្រូចនោះ
ដោយបឺតដោយបំពង់បឺត។

បន្ទាប់មកទៀតរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញ
បន្ទាប់ពីគាត់ចាក់ទឹកក្រូចឲ្យកូនស្រីរបស់គាត់ហើយ បុរសម្នាក់នោះ
គាត់ក៏បានយកស្ករសមកលាយជាមួយនឹងកាហ្វេរបស់គាត់ម្តង។ អញ្ចឹងដោយសារតែកាហ្វេខ្មៅ
គឺវាមានរសជាតិល្វីងខ្លាំង ព្រោះវាអត់មានទាន់លាយស្ករទេ អញ្ចឹងអ្នកដែលឆុងកាហ្វេ
គាត់អត់ទាន់លាយស្ករឲ្យទេ ព្រោះគាត់អត់ដឹងថាអតិថិជនរបស់គាត់ត្រូវការរសជាតិអ្វី។ ត្រូវការល្វីង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឬក៏ផ្អែម អញ្ចឹងគាត់ឆុងហើយគាត់អត់ដាក់ស្ករទេ គឺចាំឲ្យអតិថិជនរបស់គាត់លាយខ្លួនឯង។ អញ្ចឹងដោយសារតែអតិថិជនខ្លះ គឺគាត់ចូលចិត្តញ៉ាំកាហ្វេល្វីងខ្លាំង ដូច្នេះគាត់អត់លាយស្ករទេ គឺគាត់ឆុងហើយគាត់ញ៉ាំតែម្ដង។ ចំណែកអ្នកខ្លះទៀតគឺគាត់ចូលចិត្តញ៉ាំកាហ្វេដែលល្វីងតិចៗ ឬក៏ល្វីងល្មម អញ្ចឹងគាត់អាចលាយស្ករបន្ថែមមួយស្លាបព្រា ឬក៏ពីរស្លាបព្រា រួចកូរឲ្យសព្វ ដើម្បីឲ្យស្កររលាយ ហើយញ៉ាំទៅមានរសជាតិឆ្ងាញ់តាមអ្វីដែលគាត់ត្រូវការ។ ចំណែកអ្នកខ្លះទៀត គាត់អត់ចូលចិត្តល្វីងខ្លាំង អញ្ចឹងគាត់អាចលាយនឹងទឹកដោះគោ ដែលយើងហៅថា កាហ្វេទឹកដោះគោ។ អញ្ចឹងយើងអាចលាយបានច្រើន ជាក់ស្ដែងនៅក្នុងរូបភាពទី ៩ ដោយសារតែបុរសម្នាក់នោះ គាត់អត់សូវចូលចិត្តល្វីង ដូច្នេះគាត់ក៏បានយកស្ករសមួយស្លាបព្រា មកចាក់ចូលទៅក្នុងកែវកាហ្វេរបស់គាត់ ឬក៏ចាក់ចូលទៅក្នុងពែងកាហ្វេ យើងហៅថាពែងកាហ្វេ។ អញ្ចឹងគាត់យកស្ករសចាក់ចូល ដោយសារតែគាត់អត់សូវចូលចិត្តល្វីង ដូច្នេះគាត់ត្រូវការផ្អែមតិចៗ អញ្ចឹងគាត់លាយស្ករសដើម្បីឲ្យមានរសជាតិផ្អែមនៅក្នុងរូបភាពទី ៩ នេះ។

បន្ទាប់មកទៀតរូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញ បន្ទាប់ពីគាត់លាយស្ករសមួយស្លាបព្រាចូលទៅក្នុងពែងកាហ្វេរបស់គាត់ហើយ គាត់ក៏បានយកស្លាបព្រានោះមកកូរជាមួយនឹងពែងកាហ្វេរបស់គាត់ អញ្ចឹងគាត់កូរចុះកូរឡើង គាត់ធ្វើបែបនេះ ដើម្បីឲ្យស្កររលាយទៅក្នុងពែងកាហ្វេ។ អញ្ចឹងប្រសិនបើយើងគ្រាន់តែចាក់ស្ករសចូលទៅក្នុងទឹកកាហ្វេ ឬក៏កែវកាហ្វេ គឺវាអត់រលាយភ្លាមនោះទេ បានន័យថាវានឹងរលាយ ក៏ប៉ុន្តែវានឹងរលាយរយៈពេលយូរ វានឹងប្រើប្រាស់ពេលយូរដើម្បីរលាយ ដូច្នេះដើម្បីឲ្យវាឆាប់រលាយនៅក្នុងកាហ្វេ យើងត្រូវយកស្លាបព្រា យើងត្រូវយកស្លាបព្រាមកកូរនៅក្នុងទឹកកាហ្វេនោះ អញ្ចឹងយើងកូរវា យើងកូរវាពីឆ្វេងទៅស្ដាំ ឬក៏ពីស្ដាំទៅឆ្វេង ដើម្បីឲ្យស្ករសឆាប់រលាយ។ ម្យ៉ាងវិញទៀត ដោយសារតែកាហ្វេនោះជាកាហ្វេក្ដៅ ដូច្នេះនៅពេលដែលស្ករសចូលទៅក្នុងកែវកាហ្វេ គឺវាឆាប់នឹងរលាយណាស់ ដោយសារតែស្ករសគឺវាងាយនឹងរលាយនៅពេលដែលត្រូវទឹកក្ដៅ។

បន្ទាប់មកទៀតរូបភាពទី ១១ នៅក្នុងរូបភាពទី ១១ បន្ទាប់ពីគាត់កូរកែវកាហ្វេ ឬក៏កូរពែងកាហ្វេឲ្យស្កររលាយរួចរាល់ហើយ យើងឃើញបុរសម្នាក់នោះ គាត់ក៏បានលើកពែងកាហ្វេរបស់គាត់ដើម្បីញ៉ាំ។ អញ្ចឹងដោយសារតែកាហ្វេរបស់គាត់ជាកាហ្វេក្ដៅ ដូច្នេះគាត់អត់អាចប្រើប្រាស់ទុយោ ឬក៏បំពង់បឺត ដើម្បីបឺតកាហ្វេនោះចូលទៅក្នុងមាត់បានទេ។ ព្រោះប្រសិនបើគាត់ប្រើប្រាស់បំពង់បឺត វាអាចធ្វើឲ្យរលាកមាត់គាត់បាន។ ដោយសារតែការញ៉ាំកាហ្វេក្ដៅ ឬក៏ញ៉ាំទឹកក្ដៅ គឺយើងត្រូវញ៉ាំផ្ទាល់ជាមួយនឹងកែវ ដោយសារតែយើងងាយស្រួលផ្លុំ និងយើងអាចយកអណ្ដាតរបស់យើង ដើម្បីស្ទង់មើល

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឬក៏ដើម្បីវាស់កម្ដៅមើល។ អញ្ចឹងប្រសិនបើយើងញ៉ាំផ្ទាល់មាត់ជាមួយនឹងកែវ
យើងអាចយកអណ្ដាតរបស់យើងមកវាស់កម្ដៅ ថាតើវាក្ដៅល្មមនឹងញ៉ាំដែរឬទេ។
ប៉ុន្តែប្រសិនបើយើងប្រើបំពង់បឺតដើម្បីបឺតទឹកក្ដៅ គឺវាអាចធ្វើឲ្យយើងរលាកមាត់បាន
វាអាចធ្វើឲ្យមាត់យើងរលាក ព្រោះយើងអត់ដឹងថាទឹកនោះក្ដៅប៉ុណ្ណា យើងអត់បានវាស់មុន
ដូច្នេះវានឹងធ្វើឲ្យយើងរលាកបាន។ អញ្ចឹងយើងអាចប្រើប្រាស់បំពង់បឺត បឺតតែទឹកកក
និងទឹកធម្មតាតែប៉ុណ្ណោះ ប្រសិនបើទឹកក្ដៅគឺយើងអត់ត្រូវប្រើប្រាស់បំពង់បឺតនោះទេ។
ដោយយើងឃើញបុរសម្នាក់នេះ គាត់បានចាប់ដៃកែវ អញ្ចឹងពែងកាហ្វេរបស់គាត់
គឺមានដៃសម្រាប់កាន់មួយ ដូច្នេះគាត់កាន់ដៃនៃពែងកាហ្វេរបស់គាត់ ហើយគាត់លើកពែងកាហ្វេ
ដើម្បីញ៉ាំកាហ្វេនៅក្នុងពែងនោះ ដោយប្រើប្រាស់ គាត់ គាត់ញ៉ាំផ្ទាល់កែវតែម្ដង
គឺគាត់អត់ប្រើប្រាស់បំពង់បឺតនោះទេ។

បន្ទាប់មកទៀតរូបភាពទី ១២ នៅក្នុងរូបភាពទី ១២ យើងឃើញថា
បន្ទាប់ពីគាត់បានបញ្ចប់ការញ៉ាំកាហ្វេ បានន័យថាគាត់ញ៉ាំកាហ្វេអស់ហើយ
ហើយកូនស្រីរបស់គាត់ក៏បានញ៉ាំទឹកក្រូចអស់ពីក្នុងកែវផងដែរ
អញ្ចឹងកូនស្រីរបស់គាត់គឺញ៉ាំទឹកក្រូចអស់មួយកំប៉ុង វាអាចជាទឹកក្រូចកូកាកូឡា ឬក៏ទឹកក្រូច Fanta
ឬក៏ Sprite ជាដើម។ អញ្ចឹងកូនស្រីគាត់គឺញ៉ាំអស់មួយកំប៉ុង រីឯគាត់គឺញ៉ាំកាហ្វេចំនួនមួយកែវ
ឬក៏មួយពែង។ អញ្ចឹងនៅក្នុងរូបភាពទី ១២ គឺពួកគាត់ទាំងពីរគឺញ៉ាំកាហ្វេ និងញ៉ាំទឹកក្រូចអស់ហើយ
ដូច្នេះបុរសដែលជាឪពុក គាត់ក៏បានលើកដៃឡើង ដើម្បីជាសញ្ញាហៅអ្នកបម្រើ ឬក៏អ្នករត់តុមក
អញ្ចឹងយើងឃើញ បន្ទាប់ពីគាត់លើកដៃឡើងជាសញ្ញា អ្នករត់តុក៏បានមក ដោយ
យើងឃើញអ្នករត់តុនោះ គាត់មកដោយមានពាក់អៀមក្រណាត់នៅជាមួយផងដែរ
ហើយគាត់កាន់កន្សែងនៅក្នុងដៃរបស់គាត់ ដោយគាត់សួរទៅកាន់បុរសនោះ ថាតើមានការអ្វី
ព្រោះជាទូទៅ នៅពេលដែលភ្ញៀវលើកដៃឡើង គឺអ្នកបម្រើតែងតែមកសួរបញ្ជាក់ជាមួយភ្ញៀវថា
តើហៅគាត់មានការអ្វី ដោយសារតែនៅក្នុងហាង នៅពេលដែលយើងលើកដៃ គឺជាសញ្ញា
វាគឺជាសញ្ញាសម្រាប់ហៅអ្នកបម្រើ ឬក៏អ្នករត់តុ អញ្ចឹងនៅពេលដែលយើងលើកដៃនៅក្នុងហាង
គឺអ្នកបម្រើនឹងមកសួរយើងមិនខាន ហើយគេសួរថាយើងចង់បានអ្វី អញ្ចឹងបុរសម្នាក់នោះ
បន្ទាប់ពីឃើញអ្នកបម្រើគាត់មកដល់តុរបស់គាត់ គាត់ក៏បានប្រាប់អ្នកបម្រើថាឲ្យគិតលុយ
អញ្ចឹងបានន័យថា នៅពេលដែលគាត់ចប់ញ៉ាំហើយ គាត់ឈប់ញ៉ាំ
គាត់ញ៉ាំកាហ្វេនិងទឹកក្រូចអស់ហើយ គាត់ហៅអ្នកបម្រើឲ្យមកគិតលុយរបស់គាត់ថាអស់ប៉ុន្មាន
ដើម្បីគាត់បន្តដំណើរទៅកន្លែងផ្សេងទៀត។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១៣ រូបភាពទី ១៣
បន្ទាប់ពីគាត់ហៅអ្នកបម្រើឲ្យមកគិតលុយនៅតុរបស់គាត់ហើយ អញ្ចឹងរូបភាពទី ១៣ នេះ
គឺអ្នកបម្រើគាត់បានប្រាប់តម្លៃកាហ្វេរបស់គាត់ទៅដល់បុរសម្នាក់នោះ។
អញ្ចឹងដោយសារតែកាហ្វេនៅទីនេះគឺជាកាហ្វេហាង បានន័យថាគាត់ញ៉ាំកាហ្វេនៅក្នុងហាង
អញ្ចឹងយើងឃើញថាតម្លៃកាហ្វេដែលនៅក្នុងហាង គឺមានតម្លៃថ្លៃជាងកាហ្វេដែលនៅខាងក្រៅ។
បានន័យថាពេលខ្លះ កាហ្វេដែលនៅខាងក្រៅគឺមានតម្លៃត្រឹមតែពីរពាន់
ឬក៏មួយពាន់ប្រាំរយក្នុងមួយកែវតែប៉ុណ្ណោះ ចំណែកឯកាហ្វេដែលលក់តាមរទេះ
គឺមានតម្លៃតែមួយពាន់ ឬក៏មួយពាន់ប្រាំរយ[...]ក្នុងមួយកែវ
ប៉ុន្តែប្រសិនបើយើងញ៉ាំកាហ្វេនៅក្នុងហាងធំៗ ដែលជាហាងលក្ខណៈសម្រាប់ជនបរទេស គឺ
គឺមានតម្លៃថ្លៃ ដែលកាហ្វេខ្លះគឺអាចមានតម្លៃដល់ប្រាំដុល្លារ ឬក៏បីដុល្លារ ឬក៏បួនដុល្លារជាដើម។
អញ្ចឹងប្រហែលជាកាហ្វេនៅក្នុងទីនេះគឺថ្លៃ ដោយសារតែវាជាកាហ្វេហាង
និងមានអ្នករត់តុត្រឹមត្រូវផងដែរ
ដូច្នេះបន្ទាប់ពីគាត់ហៅអ្នកបម្រើឲ្យមកគិតលុយថ្លៃកាហ្វេរបស់គាត់នៅនឹងតុហើយ បុរសម្នាក់នោះ
គាត់ក៏បានដកលុយ គាត់ក៏បានដកលុយចេញពីហោប៉ៅខោរបស់គាត់ អញ្ចឹងគាត់ក៏បានដកលុយ
ហើយហុចលុយនោះទៅឲ្យអ្នកបម្រើដោយទឹកមុខញញឹម។
អញ្ចឹងបានន័យថាគាត់បញ្ចប់ការញ៉ាំកាហ្វេរបស់គាត់នៅក្នុងហាងនោះហើយ
ហើយគាត់ត្រូវបន្តដំណើរទៅមុខទៀត។ អញ្ចឹងដើម្បីទៅដើរលេងជាមួយកូនស្រីរបស់គាត់
គាត់ក៏ហៅអ្នកបម្រើឲ្យមកគិតលុយ។ អញ្ចឹងនៅក្នុងរូបភាពនេះ
គាត់ក៏បានហុចលុយថ្លៃកាហ្វេទៅឲ្យអ្នកបម្រើ រីឯអ្នកបម្រើ គាត់ក៏បានញញឹមមកដាក់បុរសនោះ
ដែលជាបុរសនោះជាអតិថិជនរបស់គាត់ ហើយគាត់ក៏បានលើកដៃទទួលលុយថ្លៃកាហ្វេ។
អញ្ចឹងនៅក្នុងរូបភាពទី ១៣ យើងឃើញម្នាក់ប្រគល់លុយ និងម្នាក់ទទួលលុយថ្លៃកាហ្វេ
ហើយពួកគេទាំងពីរអ្នកគឺមានទឹកមុខញញឹមដូចគ្នា ព្រោះបុរសម្នាក់នោះ
គាត់បាននាំកូនស្រីរបស់គាត់មកញ៉ាំកាហ្វេនៅក្នុងហាង រីឯអ្នកបម្រើនោះ
គាត់មានអតិថិជនចូលក្នុងហាងរបស់គាត់ ដូច្នេះពួកគេទាំងពីរអ្នកគឺសប្បាយរីករាយ។

បន្ទាប់មកទៀតរូបភាពចុងក្រោយ រូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ យើងឃើញថា
បន្ទាប់ពីពួកគាត់ញ៉ាំកាហ្វេរួចរាល់ហើយ អញ្ចឹងបានន័យថាពួកគាត់បញ្ចប់ការញ៉ាំកាហ្វេរបស់ពួកគាត់
ដោយបុរសម្នាក់នោះ គាត់ញ៉ាំកាហ្វេខ្មៅហើយក្តៅ អញ្ចឹងគាត់ញ៉ាំកាហ្វេខ្មៅ
ហើយក្មេងស្រីដែលជាកូនស្រីរបស់គាត់ គឺញ៉ាំទឹកក្រូច អាចជាទឹកក្រូចកូកាកូឡា ឬក៏ទឹកក្រូច Fanta
ឬក៏ Sprite ជាដើមហ្នឹង។ អញ្ចឹងបន្ទាប់ពីគាត់ញ៉ាំហើយ ពួកគាត់ទាំងពីរអ្នកក៏បានចេញពីហាង
ក្រោយពីគាត់គិតលុយរួច។ អញ្ចឹងមុនពេលដែលយើងចេញពីហាង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

យើងត្រូវហៅអ្នកបម្រើមកគិតលុយជាមុនសិន ដើម្បីទូទាត់ថាតើយើងញុាំអស់ប៉ុន្មាន។
អញ្ចឹងបន្ទាប់ពីគាត់ទូទាត់លុយ និងគិតលុយរួចរាល់ហើយ បុរសម្នាក់នោះ
គាត់ក៏បានដឹកដៃកូនស្រីរបស់គាត់ចេញពីហាង និងបន្តដំណើរទៅខាងមុខទៀត
ដែលគាត់មិនបានលែងដៃកូនស្រីរបស់គាត់ទេ ទោះបីជាគាត់ចេញពី ចូលទៅក្នុងហាង
ហើយនិងចេញពីហាងមកវិញក៏ដោយ គឺគាត់នៅតែដើរកាន់ដៃកូនស្រីរបស់គាត់ដដែល
ដោយសារតែ[...]គាត់ខ្លាចកូនស្រីរបស់គាត់ហ្នឹងគឺរត់លេងផ្ដេសផ្ដាស
អញ្ចឹងគាត់ខ្លាចកូនស្រីរបស់គាត់រត់លេងផ្ដេសផ្ដាស ទៅលើថ្នល់
ឬក៏រត់លេងទៅបុកទង្គិចនឹងវត្ថុផ្សេងៗដែលនៅតាមផ្លូវ
អាចធ្វើឲ្យកូនស្រីរបស់គាត់ហ្នឹងមានគ្រោះថ្នាក់ ដោយសារតែនាងនៅតូច។
អញ្ចឹងដោយសារតែនាងនៅតូច ដូច្នេះគាត់ត្រូវដើរដឹកដៃនាងឲ្យបានជាប់ ដើម្បីកុំឲ្យវង្វេងផង
និងដើម្បីការពារសុវត្ថិភាពកូនស្រីរបស់គាត់ កុំឲ្យមានគ្រោះថ្នាក់ផងនៅពេលដែលគាត់ធ្វើដំណើរ
ព្រោះជាទូទៅការធ្វើដំណើរនៅតាមផ្លូវតែងតែមានម៉ូតូឡានជាច្រើនដែលបើកបរ
ដូច្នេះវាងាយនឹងមានគ្រោះថ្នាក់ខ្លាំងណាស់សម្រាប់ក្មេងតូចៗ ដោយសារតែក្មេងតូចៗគឺតែងតែរពឹស
អញ្ចឹងក្មេងតូចៗគឺរពឹស ដូច្នេះយើងត្រូវតែការពារ និងមើលថៃក្មេងតូចៗ ឲ្យបានល្អជានិច្ច
ដើម្បីកុំឲ្យនាងមានគ្រោះថ្នាក់ និងវង្វេងផ្លូវបាន។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.